តាមការប៉ាន់ប្រមាណស្ថានភាពទូទៅ នៃការរីករាលដាលមេរោគអេដស៍នៅកម្ពុជានាពេលបច្ចុប្បន្ននេះបានបង្ហាញថា អត្រាឆ្លងមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅដែលមានអាយុចន្លោះពី១៥ ដល់ ៤៩ ឆ្នាំមានប្រមាណ ០ ៧.ភាគរយក្នុងឆ្នាំ ២០១៣។ តាមការសិក្សាបានបញ្ជាក់ថា អត្រាឆ្លងមេរោគអេដស៍ខ្ពស់ គឺស្ថិតក្នុងចំណោមបីក្រុមសំខាន់ៗមានដូចជា ក្រុមធ្វើការនៅកន្លែងសេវាកំសាន្តសប្បាយ (Entertainment Workers)មានប្រមាណជា១៤ភាគរយ៧. ក្រុមបុរសស្រឡាញ់បុរស (Men who having sex with Men) មានប្រមាណ២ភាគរយ១. និងក្រុមអ្នកប្រប្រាស់គ្រឿងញៀន )People who Use Drug/People who Injecting Drug) មានប្រមាណ២៤ភាគរយ៨.។ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស (MSM) អត្រាឆ្លងមានប្រមាណ ៨៧. ភាគរយក្នុងទីក្រុងភ្នំពេញ និងប្រមាណជា០ភាគរយនៅតាមបណ្តាខេត្ត៨.មួយចំនួនដូចជា បាត់ដំបង និងសៀមរាប។ ដោយផ្អែកលើតួលេខក្នុងរបាយការណ៍អង្កេតក្នុងឆ្នាំ២០០៧ បានបង្ហាញថាអត្រាឆ្លងមេរោគអេដស៍មានកម្រិតខ្ពស់ក្នុងចំណោមស្រីស្រស់.៩មានរហូតដល់ (ប្រុសដែលតែងខ្លួនដូចជាស្រី)៨ភាគរយ បើប្រៀបធៀបទៅនឹងបុរសស្រឡាញ់បុរសធម្មតាមានប្រមាណជា០ភាគរយប៉ុណ្ណ៥.ណោះ។

ការសិក្សាអំពីប្រុសខ្មែរដោយអង្គការ FHI360 និងNCHADS នៅឆ្នាំ២០១០បានបង្ហាញថា អត្រាប្រេវ៉ាឡង់ នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមក្រុបស្រីស្រស់ខ្ពស់ជាងក្រុមបុរសរួមភេទជាមួយ (២៦%)ធៀបនិង(១៩%)។ ជាងនេះទៀតអាត្រាប្រេឡងនៃការឆ្លងជំងឺកាមរោគ (ដោយគិតបញ្ចូលទាំងការបង្ករោគដោយ Chlamydia និង Gonorrhea នៅរន្ធគូថឬជំងឺស្វាយ) មាន២១% ចំពោះក្រុមស្រីស្រស់ រីឯក្រុមបុរសរួមភេទជាមួយបុរសមានតែ ៧% ប៉ុណ្ណោះ។

## ២. និយមន័យនៃពាក្យបុរសស្រឡាញ់បុរស (MSM) និងស្រីស្រស់ (TG)

និយមន័យនៃពាក្យបុរសស្រឡាញ់បុរស និងស្រីស្រស់ ត្រូវបានគេឱ្យនិយមន័យជាច្រើនខុសប្លែកគ្នាទៅតាមស្ថានភាព ឥរិយាបទ និងការប្រឈមរបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។ ប៉ុន្តែតាមរយៈក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ បានកំណត់និយមន័យ បុរសស្រឡាញ់បុរស និងស្រីស្រស់ ដូចខាងក្រោម:

- បុរសស្រឡាញ់បុរស (Men who having Sex with Men) : ជាពាក្យត្រូវបានប្រើសម្រាប់សំដៅលើបុរសរួមភេទជាមួយបុរសដទៃទៀត។ ពាក្យនេះមិនចាំបាច់មានន័យថា MSM មានអត្តសញ្ញាណ ឬ ក៏មានសហគមន៍ដែលពួកគេរស់នៅតែផ្អែកលើកត្តាដែលពួកគេរួមភេទជាមួយបុរសឯទៀត MSM ខ្លះមានអត្តសញ្ញាណបែបនេះក៏ដោយ។ ពាក្យ MSM ត្រូវបានប្រើដោយរួមទាំង Transgender

ដែលអាចមិនកំណត់ខ្លួនឯងថាជាបុរស។បន្ថែមលើការរួមភេទជាមួយបុរស MSM អាចរួមភេទជាមួយស្ត្រីផងដែរ។

- ស្រីស្រស់ (Transgender) គឺសំដៅទៅលើបុរសដែលកំណត់ខ្លួន ឯងថាភេទស្រី ហើយបានស្លៀកពាក់ជាស្រី មានឥរិយាបថ និងចរិកលក្ខណៈជាស្ត្រី។

### ៣. ស្ថិតិបុរសស្រឡាញ់បុរស និងស្រីស្រស់នៅកម្ពុជា

តាមការប៉ាន់ប្រមាណថ្នាក់ជាតិ នៅកម្ពុជាមានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រហែល ២១.០០០ នាក់ ក្នុងនោះ មាននៅតាមបណ្តារាជធានី និងខេត្តដូចខាងក្រោម:

| *ល.រ* | *រាជធានី-ខេត្ត* | *ចំនួន បុរសស្រឡាញ់បុរស* | *ចំនួនស្រីស្រស់* | *សរុប* |
|---|---|---|---|---|
| ១ | ភ្នំពេញ | ៥៩០៣ | | ៥៩០៣ |
| ២ | សៀមរាប | ៩៨៩ | ៣០០ | ១២៨៩ |
| ៣ | បាត់ដំបង | ២៤៤០ | ២០៧ | ២៦៤៧ |
| ៤ | បន្ទាយមានជ័យ | ២៣៦២ | | ២៣៦២ |
| ៥ | កណ្តាល | ១០៩១ | | ១០៩១ |
| ៦ | កំពង់ចាម | ៨៥៧ | ៨០ | ៩៣៧ |
| ៧ | កំពង់ឆ្នាំង | ៧៦០ | | ៧៦០ |
| ៨ | កំពង់ស្ពឺ | ៧៦៨ | | ៧៦៨ |
| ៩ | កំពង់ធំ | ៥៥១ | ៤៦ | ៥៨៧ |
| ១០ | ព្រះសីហនុ | ៦០០ | | ៦០០ |
| ១១ | ពោធិសាត់ | ៥៨៧ | | ៥៨៧ |
| ១២ | ព្រៃវែង | ៥១៧ | | ៥១៧ |
| ១៣ | ប៉ៃលិន | ៣៩៣ | | ៣៩៣ |
| | សរុប | | | ១៨៧៩៣ |

### ៤. បទអន្តរាគមន៍សំខាន់សម្រាប់ក្រុមបុរសស្រឡាញ់បុរស

កិច្ចបង្ការ ការពារ និងគាំទ្រសម្រាប់ក្រុមបុរសស្រឡាញ់បុរស